ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៥៥ ......សហវ

# ប្រកាស
# ស្តីពី
# ការអនុវត្តអាករលើតម្លៃបន្ថែម
# លើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់អំពីយន្តការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ស្របតាមអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅដាក់ចេញនូវយន្តការលើកលែងអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដើម្បីគាំទ្រដល់គោលនយោបាយនាំចេញអង្ករបស់រាជរដ្ឋាភិបាល និងសម្រាលបន្ទុកចំណាយរបស់ប្រជាជនក្នុងការប្រើប្រាស់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដែលក្នុងនោះមានគ្រាប់ធញ្ញជាតិនានា រួមទាំងស្រូវអង្ករផង។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ "ផលិតផលកសិកម្មមិនទាន់កែច្នៃ" សំដៅដល់ ឫស មើម ដើម សំបក ផ្លែ ផ្កា ឬគ្រាប់ នៃរុក្ខជាតិ ដែលបានមកពីការធ្វើកសិកម្មដាំដុះ ទោះមិនទាន់កិនឬកិនបំបែករួចហើយក្តី និងដែលមិនទាន់ត្រូវបានយកទៅកែច្នៃជាផលិតផលផ្សេង។

២- ពាក្យ "ផ្គត់ផ្គង់" សំដៅដល់ ÷

ក. ការលក់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. ការដកយកផលិតផលកសិកម្មមិនទាន់កែច្នៃ មកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ

គ. ការផ្តល់ជាអំណោយឬការលក់ក្រោមតម្លៃពិតនូវផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាករ

ឃ. ការនាំចូលផលិតផលកសិកម្មមិនទាន់កែច្នៃ មកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។

៣- ពាក្យ "បុគ្គលជាប់អាករ" សំដៅដល់បុគ្គលទាំងឡាយដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

**ប្រការ ៥.- ការលើកលែងអាករលើតម្លៃបន្ថែម**

ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ។

**ប្រការ ៦.-  ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ធ្វើកសិកម្មដាំដុះផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា ២៩ ដល់មាត្រា ៤១ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៧.-  ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ